**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :..៦៤..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៥.០៣០,៥១ ហិកតា នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងនោះ កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ឹមឌីអេសនីហ័រណោ សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៦៣ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៧៤ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០១៣៣ ខ.ពស ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ថ្ងៃដីសរុបទំហំ ៥.០៣០,៥១ ហិកតា ក្នុងនោះ ទំហំ ៤.៣៣៣,៣៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៧៤ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងទំហំ ៦៩៧,១៦ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ឹមឌីអេស នីហ័រណេ ដើម្បីធ្វើប្រទានកម្មទំហំ ៣.៨៥១,៩៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១.១៧៨,៥៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

១. ភូមិទំព័រ ឃុំប្រមោយ៖

- ផ្ទៃដីទំហំ ៣៧២,២៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ទំហំ ២០៩,១៦ ហិកតា ជូនប្រជាពលរដ្ឋ ៩៧ គ្រួសារ និងទំហំ ១៦៣,០៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ។

២. ភូមិក្រពើពីរលើ ឃុំក្រពើពីរ ៖

- ផ្ទៃដីទំហំ ១.២៤៩,៧៧ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ទំហំ ៨៨៧,៣៥ ហិកតា ជូនប្រជាពលរដ្ឋ ២០៨ គ្រួសារ និង ទំហំ ៣៦២,៤២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ។



p

៣. ភូមិកណ្តាល ឃុំអន្លង់រាប៖

- ផ្ទៃដីទំហំ ១.២១៤,៩៥ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ទំហំ ៨៤៥,៥៨ ហិកតា ជូនប្រជាពលរដ្ឋ ២៧៤ គ្រួសារ និងទំហំ ៣៦៩,៣៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ
- ផ្ទៃដីទំហំ ៣៦៨,១០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអ៊ឹមឌីអេសនីហ៍រណេ សម្រាប់ធ្វើប្រទានកម្មទំហំ ៣០០,០៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៨,០៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ។

៤. ភូមិក្រាំងរងៀង ឃុំអន្លង់រាប៖

- ផ្ទៃដីទំហំ ៣៦ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ទំហំ ២៣,៩៩ ហិកតា ជូនប្រជាពលរដ្ឋ ៨៨ គ្រួសារ និង ទំហំ ១២,០១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ។

៥. ភូមិចំការជ្រៃខាងជើង ឃុំអន្លង់រាប៖

- ផ្ទៃដីទំហំ ៦៥,២១ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ទំហំ ៤៧,១៦ ហិកតា ជូនប្រជាពលរដ្ឋ ៨១ គ្រួសារ និង ទំហំ ១៨,០៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ
- ផ្ទៃដីទំហំ ១៦៧,៥១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ឹមឌីអេស នីហ៍រណេ សម្រាប់ធ្វើប្រទានកម្មទំហំ ១៤៤,៩១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២២,៦០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ។

៦. ភូមិចំការជ្រៃខាងត្បូង ឃុំអន្លង់រាប៖

- ផ្ទៃដីទំហំ ១.៣៩៥,១៧ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ទំហំ ១.២៥៥,១២ ហិកតា ជូនប្រជាពលរដ្ឋ ៣២៨ គ្រួសារ និងទំហំ ១៤០,០៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ
- ផ្ទៃដីទំហំ ១៦១,៥៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អ៊ឹមឌីអេស នីហ៍រណេ សម្រាប់ធ្វើប្រទានកម្មទំហំ ១៣៨,៦៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២២,៨៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ

តាមប្រព័ន្ធភូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) (២) (៣) (៤) និង(៥) នៃអនុក្រឹត្យនេះ ។

**មាត្រា ២..**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជន ជូនប្រជាពលរដ្ឋ ចំនួន ១.២៦៣ គ្រួសារ ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

**១. ភូមិទំព័រ ឃុំប្រមោយ ៖**

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៧ គ្រួសារ

**២. ភូមិក្រពើពីរលើ ឃុំក្រពើពីរ ៖**

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៨ គ្រួសារ

**៣. ភូមិកណ្តាល ឃុំអន្លង់រាប៖**

- ផ្ទៃដីកាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៤ គ្រួសារ
- ផ្ទៃដីកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអ៊ឹមឌីអេសនីហ័រណេ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៩ គ្រួសារ

**៤. ភូមិក្រាំងរងៀង ឃុំអន្លង់រាប៖**

- ផ្ទៃដីកាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៨ គ្រួសារ

**៥. ភូមិចំការជ្រៃខាងជើង ឃុំអន្លង់រាប៖**

- ផ្ទៃដីកាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨១ គ្រួសារ
- ផ្ទៃដីកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអ៊ឹមឌីអេស នីហ័រណេ ប្រទានកម្មជាម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៩ គ្រួសារ

**៦. ភូមិចំការជ្រៃខាងត្បូង ឃុំអន្លង់រាប៖**

- ផ្ទៃដីកាត់ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២៨ គ្រួសារ
- ផ្ទៃដីកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអ៊ឹមឌីអេសនីហ័រណេ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៩ គ្រួសារ ។

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តពោធិ៍សាត់ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។



p

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*



p